# ផ្នែកទី I ( i )

# ផ្លាកសញ្ញាបំរាម

## Prohibitory signs

ផ្លាកសញ្ញាបំរាមមានរាងមូល មានជាយពទ្ធ័ជុំវិញពីរជាន់ ជាយក្នុងក្រាស់មានពណ៌ក្រហមក្រាស់ជាយក្រៅ ស្តើងមានពណ៌ស ឯសញ្ញាសំគាល់ខាងក្នុងជាទូទៅមានពណ៌ខ្មៅ ។ ក្នុងករណីខ្លះត្រូវប្រើសញ្ញាចប់ការហាម ឃាត់ ដែលមានរាងមូលដូចគ្នា តែមានពណ៌ខ្មៅទាំងអស់ ។

ផ្លាកសញ្ញាប្រភេទនេះ ដាក់បំរាមដល់អ្នកបើកបរមិនអោយប្រព្រឹត្តិនូវអ្វី ដែលមានបញ្ជាក់នៅក្នុង សញ្ញាដូចជា ហាមបត់ឆ្វេង ហាមបត់ស្តាំ ហាមចត ។ល។ ដូចនេះបើអ្នកបើកបរ ឃើញផ្លាកសញ្ញាប្រភេទនេះ ត្រូវអនុវត្ត តាមជាដាច់ខាត ។

## ផ្នែកទី I ( i ) : ផ្លាកសញ្ញាបំរាម ( Prohibitory Signs )



**ហាមបត់ឆ្វេង**

NO TURN LEFT

**លេខកូដ : PW03-R1-01**

**ខ្លឹមសារ** : សញ្ញានេះ ហាមយានជំនិះគ្រប់ប្រភេទ បត់ឆ្វេង ។

---



**ហាមបត់ស្តាំ**

NO TURN RIGHT

**លេខកូដ : PW03-R1-02**

**ខ្លឹមសារ** : សញ្ញានេះ ហាមយានជំនិះគ្រប់ប្រភេទ បត់ស្តាំ ។

---



**ហាមបត់ត្រឡប់ក្រោយ**

NO **U** TURN

**លេខកូដ : PW03-R1-03**

**ខ្លឹមសារ** : សញ្ញានេះ ហាមយានជំនិះគ្រប់ប្រភេទ បត់ត្រឡប់ក្រោយ ។

---



**ហាមចូល**

NO ENTRY

**លេខកូដ : PW03-R1-04**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះគ្រប់ប្រភេទ ។



**ផ្លូវបិទចំពោះយានជំនិះគ្រប់ប្រភេទ**

CLOSED FOR ALL VEHICLES

**លេខកូដ : PW03-R1-05**

**ខ្លឹមសារ** : ផ្លូវបិទ ចំពោះយានជំនិះគ្រប់ប្រភេទ ។

---



**ផ្លូវបិទ ចំពោះអ្នកប្រើប្រាស់ផ្លូវ**

CLOSED FOR ALL ROAD USERS

**លេខកូដ : PW03-R1-06**

**ខ្លឹមសារ** : ផ្លូវបិទចំពោះអ្នកប្រើប្រាស់ផ្លូវ (ហាមយានជំនិះគ្រប់ប្រភេទ និង ថ្មើរជើងធ្វើចរាចរ) ។

---




**កំណត់ទំងន់សរុប**

TOTAL WEIGHT LIMIT

**លេខកូដ : PW03-R1-07**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះដែលមានទំងន់សរុបគិតទាំងបន្ទុក លើសទំងន់កំណត់ក្នុង ផ្លាកសញ្ញា។

---




**កំណត់ទំងន់ផ្ទុកលើភ្លៅនិមួយៗ**

WEIGHT LIMIT ON ONE AXLE

**លេខកូដ : PW03-R1-08**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះដែលមានទំងន់ផ្ទុកលើភ្លៅ ( ប៉ុង ) និមួយៗ លើសពីការកំណត់ក្នុង ផ្លាក សញ្ញា ។




### កំណត់កំពស់

HEIGHT LIMIT

**លេខកូដ : PW03-R1-09**

**ខ្លឹមសារ** : សញ្ញានេះហាមចូលចំពោះយានជំនិះដែលមាន កំពស់ សរុប គិតទាំងបន្ទុក លើសកំពស់កំណត់ ក្នុងផ្លាក សញ្ញា ។

---




### កំណត់ទទឹង

WIDTH LIMIT

**លេខកូដ : PW03-R1-10**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះ ដែលមាន ទទឹង សរុប គិតទាំងបន្ទុក លើសប្រវែងកំណត់ ក្នុងផ្លាក សញ្ញា ។

---




### កំណត់បណ្ដោយ

LENGHT LIMIT

**លេខកូដ : PW03-R1-11**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះ ដែលមាន បណ្ដោយ សរុប គិតទាំងបន្ទុក លើសប្រវែងកំណត់ ក្នុងផ្លាកសញ្ញា ។

---



### ហាមចូលចំពោះទោចក្រយាន ទោចក្រយានយន្ត និង ត្រីចក្រយាន

NO ENTRY FOR BICYCLE , MOTORCYCLE AND TRICYCLE

**លេខកូដ : PW03-R1-12**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះ ទោចក្រយាន, ទោចក្រយានយន្ត និង ត្រីចក្រយាន ។



**ហាមចូលចំពោះ ទោចក្រយានយន្ត**

NO ENTRY FOR MOTORCYCLE

**លេខកូដ : PW03-R1-13**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះទោចក្រយានយន្ត។

---



**ហាមចូលចំពោះយានយន្តគ្រប់ប្រភេទ លើកលែងតែទោចក្រយានយន្ត**

NO ENTRY FOR MOTOR VEHICLES EXCEPT MOTORCYCLES WITHOUT SIDE CARTS

**លេខកូដ : PW03-R1-14**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះ យានយន្តគ្រប់ប្រភេទ លើកលែងតែ ទោចក្រយានយន្ត ដែលគ្មានភ្ជាប់រ៉ឺម៉ក សណ្តោង ឬ រ៉ឺម៉កចំហៀង។

---



**ហាមចូលចំពោះរថយន្តដឹកទំនិញធុនធំ**

NO ENTRY FOR LARGED-SIZED TRUCK

**លេខកូដ : PW03-R1-15**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះ រថយន្តដឹកទំនិញធុនធំដែលជាប្រភេទរថយន្ត មានទំងន់សរុបលើស ៣.៥០តោន ។

---



**ហាមចូលចំពោះរថយន្តដឹកអ្នកដំណើរធុនធំ**

NO ENTRY FOR LARGED-SIZED BUS

**លេខកូដ : PW03-R1-16**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះ រថយន្តដឹកអ្នកដំណើរធុនធំ ដែលជា ប្រភេទរថយន្ត ផ្ទុកអ្នកដំណើរលើសពី ២០ នាក់ គិតទាំងអ្នកបើកបរ ។



**ហាមចូលចំពោះយានយន្តគ្រប់ប្រភេទ**

NO ENTRY FOR MOTOR VEHICLES

**លេខកូដ : PW03-R1-17**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានយន្តគ្រប់ប្រភេទ ។

---



**ហាមចូលចំពោះ ទោចក្រយាន**

NO ENTRY FOR BICYCLE

**លេខកូដ : PW03-R1-18**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះទោចក្រយាន ។

---



**ហាមចត**

NO PARKING

**លេខកូដ : PW03-R1-19**

**ខ្លឹមសារ** : សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទ, បុន្តែអ្នកបើកបរអាចឈប់ដាក់មនុស្ស ឬ ទំនិញ ឡើងចុះ ក្នុងរយៈពេលចាំបាច់ ។

---



**ហាមឈប់**

NO STOPPING

**លេខកូដ : PW03-R1-20**

**ខ្លឹមសារ** : សញ្ញានេះ ហាមឈប់ ចំពោះយានជំនិះគ្រប់ប្រភេទ ។




## ហាមចតចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ១៥

NO PARKING FROM 1st TO 15th OF MONTH

**លេខកូដ : PW03-R1-21**

**ខ្លឹមសារ :** សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទចាប់ពីថ្ងៃទី១ ដល់ ថ្ងៃទី១៥ នៃខែនិមួយៗ ប៉ុន្តែអ្នកបើកបរអាចឈប់ដាក់មនុស្ស ឬ ទំនិញឡើងចុះ ក្នុងរយៈពេលចាំបាច់ ។ ការផ្លាស់ប្តូររវាង ថ្ងៃទី១៥ ទៅ ថ្ងៃទី១៦ ប្រព្រឹត្តទៅនៅចន្លោះម៉ោង ២១:០០ ទៅ ២១:៣០ ។

---




## ហាមចតចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ៣១

NO PARKING FROM 16th TO 31st OF MONTH

**លេខកូដ : PW03-R1-22**

**ខ្លឹមសារ :** សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទចាប់ពីថ្ងៃទី១៦ ដល់ ថ្ងៃដាច់ខែ នៃខែនិមួយៗ ប៉ុន្តែអ្នកបើកបរអាចឈប់ដាក់មនុស្ស ឬ ទំនិញឡើងចុះ ក្នុងរយៈពេលចាំបាច់ ។ ការផ្លាស់ប្តូររវាង ថ្ងៃដាច់ខែ ទៅ ថ្ងៃទី១ នៃខែបន្ទាប់ ប្រព្រឹត្តទៅនៅចន្លោះម៉ោង ២១:០០ ទៅ ២១:៣០ ។

---




## ហាមចតថ្ងៃសេស

NO PARKING ON ODD DAYS

**លេខកូដ : PW03-R1-23**

**ខ្លឹមសារ :** សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទនៅថ្ងៃសេស នៃខែនិមួយៗ ប៉ុន្តែអ្នកបើកបរអាច ឈប់ដាក់មនុស្ស ឬ ទំនិញឡើងចុះក្នុងរយៈពេលចាំបាច់ ។ ការផ្លាស់ប្តូររវាង ថ្ងៃសេស ទៅថ្ងៃគត់គូរ ប្រព្រឹត្តទៅនៅចន្លោះម៉ោង ២១:០០ ទៅ ២១:៣០ ។

---




## ហាមចតថ្ងៃគត់គូរ

NO PARKING ON EVEN DAYS

**លេខកូដ : PW03-R1-24**

**ខ្លឹមសារ :** សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទនៅថ្ងៃគត់គូរ នៃខែនិមួយៗ ប៉ុន្តែអ្នកបើកបរអាច ឈប់ដាក់មនុស្ស ឬ ទំនិញឡើងចុះក្នុងរយៈពេលចាំបាច់ ។ ការផ្លាស់ប្តូររវាង ថ្ងៃគត់គូរ ទៅថ្ងៃសេស ប្រព្រឹត្តទៅនៅចន្លោះម៉ោង ២១:០០ ទៅ ២១:៣០ ។



**ហាមជែង**

NO OVERTAKING

**លេខកូដ : PW03-R1-25**

**ខ្លឹមសារ** : សញ្ញានេះ ហាមជែង ចំពោះយានយន្តគ្រប់ប្រភេទ លើកលែងតែទោចក្រយានយន្ត ។

---



**ចប់ការហាមជែង**

END OF NO OVERTAKING

**លេខកូដ : PW03-R1-26**

**ខ្លឹមសារ** : សញ្ញានេះ ចប់ការហាមជែងចំពោះយានយន្តគ្រប់ប្រភេទ ។

---



**ហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំ**

NO OVERTAKING FOR LARGE-SIZE TRUCK

**លេខកូដ : PW03-R1-27**

**ខ្លឹមសារ** : សញ្ញានេះ ហាមរថយន្តដឹកទំនិញធន់ធំ (ដែលមានទំងន់សរុប លើស ៣,៥០តោន) ជែង យានយន្តផ្សេងទៀត លើកលែងតែទោចក្រយានយន្ត ។

---



**ចប់ការហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំ**

END OF NO OVERTAKING FOR LARGE-SIZE TRUCK

**លេខកូដ : PW03-R1-28**

**ខ្លឹមសារ** : សញ្ញានេះ ចប់ការហាមរថយន្តដឹកទំនិញធន់ធំ (ដែលមានទំងន់សរុប លើស ៣,៥០តោន) ជែង យានយន្តផ្សេងទៀត ។



**ហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំដូចគ្នា**

NO OVERTAKING FOR SAMILAIR LARGE-SIZE TRUCK

**លេខកូដ : PW03-R1-29**

**ខ្លឹមសារ :** សញ្ញានេះ ហាមចំពោះជែងរវាងរថយន្តដឹកទំនិញធន់ធំ ដូចគ្នា ។

---



**ចប់ការហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំដូចគ្នា**

END OF NO OVERTAKING FOR SAMILAIR LARGE-SIZE TRUCK

**លេខកូដ : PW03-R1-30**

**ខ្លឹមសារ :** សញ្ញានេះ ចប់ការហាមចំពោះជែង រវាងរថយន្តដឹកទំនិញធន់ធំដូចគ្នា ។

---



**ហាមស៊ីផ្លេ**

NO HORN

**លេខកូដ : PW03-R1-31**

**ខ្លឹមសារ :** សញ្ញានេះ ហាមស៊ីផ្លេ ចំពោះយានជំនិះគ្រប់ប្រភេទ លើកលែងតែករណីអាចមានគ្រោះថ្នាក់បន្ទាន់ ។

---



**ចប់ការហាមស៊ីផ្លេ**

END OF NO HORN

**លេខកូដ : PW03-R1-32**

**ខ្លឹមសារ :** សញ្ញានេះ ចប់ការហាមស៊ីផ្លេ ចំពោះយានជំនិះគ្រប់ប្រភេទ ។



**ហាមចូលចំពោះទោចក្រយានយន្តមានសណ្តោង**

NO ENTRY FOR MOTORCYCLE DRAWN VEHICLES

**លេខកូដ : PW03-R1-33**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះទោចក្រយានយន្ត ដែលមានសណ្តោងរ៉ឺម៉ក ឬ រទេះ ។

---



**ហាមចូលចំពោះរទេះអូសទាញដោយសត្វ**

NO ENTRY FOR ANIMAL DRAWN VEHICLES

**លេខកូដ : PW03-R1-34**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះរទេះ ដែលអូសទាញដោយសត្វ ។

---



**ហាមអូស ឬ រុញរទេះចូល**

NO ENTRY FOR HAND-CARTS

**លេខកូដ : PW03-R1-35**

**ខ្លឹមសារ :** សញ្ញានេះ ហាមអូស ឬ រុញរទេះចូល ។

---



**ហាមចូលចំពោះ យានយន្តកសិកម្ម**

NO ENTRY FOR AGRICULTURAL MOTOR VEHICLES

**លេខកូដ : PW03-R1-36**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះយានយន្តកសិកម្ម គ្រប់ប្រភេទ ។



**ហាមចូលចំពោះរថយន្តដឹកទំនិញធុនធំមានសណ្តោង**

NO ENTRY FOR COMBINATION VEHICLES

**លេខកូដ : PW03-R1-37**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូល ចំពោះរថយន្តដឹកទំនិញធុនធំមានសណ្តោង (រ៉ឺម៉ក) ។

---




**ចន្លោះសុវត្ថិភាព រវាងរថយន្តធុនតូច**

SAFETY DISTANCE BETWEEN PASSENGER CARS

**លេខកូដ : PW03-R1-38**

**ខ្លឹមសារ :** សញ្ញានេះ ហាមអ្នកបើកបររថយន្តធុនតូចដូចគ្នា ទុកចន្លោះសុវត្ថិភាព តិចជាងចំងាយ ដូចមានកំណត់ក្នុងផ្លាកសញ្ញា ។

---




**ចន្លោះសុវត្ថិភាព រវាងរថយន្តធុនធំ**

SAFETY DISTANCE BETWEEN TRUCKS.

**លេខកូដ : PW03-R1-39**

**ខ្លឹមសារ :** សញ្ញានេះ ហាមអ្នកបើកបររថយន្តធុនធំដូចគ្នា ទុកចន្លោះសុវត្ថិភាព តិចជាងចំងាយ ដូចមានកំណត់ក្នុងផ្លាកសញ្ញា ។

---



**ហាមចូល ចំពោះយានយន្តដឹកផលិតផលងាយឆេះ ឬឆេះ**

NO ENTRY FOR VEHICLE LOADING INFLAMMABLE OR EXPLOSABLE GOODS

**លេខកូដ : PW03-R1-40**

**ខ្លឹមសារ :** សញ្ញានេះហាមចូលចំពោះយានយន្តដែលដឹកផលិតផលងាយឆេះ ឬឆេះ ដូចជា រំសេវ ឧស្ម័ន ឬប្រេងឥន្ធនៈ ។ល។




**កំណត់ល្បឿនអតិបរិមា**

MAXIMUM SPEED LIMIT

**លេខកូដ : PW03-R1-41**

**ខ្លឹមសារ :** សញ្ញានេះ ហាមយានយន្តគ្រប់ប្រភេទ បើកបរលើសល្បឿន (គិតជាគីឡូម៉ែត្រក្នុង១ម៉ោង ) ដូចមានកំណត់ក្នុងផ្លាកសញ្ញា ។

---




**ចប់ការ កំណត់ល្បឿនអតិបរិមា**

END OF MAXIMUM SPEED LIMIT

**លេខកូដ : PW03-R1-42**

**ខ្លឹមសារ :** សញ្ញានេះ ចប់ការហាមចំពោះយានយន្តគ្រប់ប្រភេទ បើកបរលើសល្បឿន ដូចមានកំណត់ក្នុងផ្លាកសញ្ញា ។




**ឈប់នៅទីស្នាក់ការគយ**

STOP AT THE CUSTOMS STATION

**លេខកូដ : PW03-R1-43**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ ឈប់នៅទីស្នាក់ការគយ ដើម្បីធ្វើការត្រួតពិនិត្យ និង បំពេញបែបបទ ។

---




**ឈប់នៅទីស្នាក់ការប៉ូលីស**

STOP AT THE POLICE STATION

**លេខកូដ : PW03-R1-44**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះស៊ីវិល គ្រប់ប្រភេទ ឈប់នៅ ទីស្នាក់ការនគរបាលដើម្បីធ្វើការត្រួតពិនិត្យ ។




**ឈប់នៅទីស្នាក់ការអាវុធហត្ថ**

STOP AT THE MILITARY POLICE STATION

**លេខកូដ : PW03-R1-45**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះ គ្រប់ប្រភេទ របស់កងកំលាំងប្រដាប់អាវុធ ឈប់នៅទីស្នាក់ការ អាវុធហត្ថ ដើម្បីធ្វើការត្រួតពិនិត្យ ។